**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

មជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម
មកដល់. ថ្ងៃទី.០៣...ខែ.សីហា.ឆ្នាំ.២០១៦
លេខ.......២១៤.......
ម៉ោង.......ល្ងាច.......

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ ៦១៥០/៦៣៧ កសក.គហ

រាជធានីភ្នំពេញ, ថ្ងៃទី...២៩.....ខែ..កក្កដា..ឆ្នាំ ២០១៦

**ជម្រាបមក**

**-ឯកឧត្តម លោក លោកស្រីប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**-លោកប្រធានមន្ទីរកសិកម្មរាជធានី ខេត្ត**

**កម្មវត្ថុ** : សំណើបញ្ឈប់ការប្រើប្រាស់ស្លាកលេខរថយន្ត និងម៉ូតូ ដែលបានជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ របស់អង្គភាព និងមន្ទីរកសិកម្មរាជធានី ខេត្ត។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាប **ឯកឧត្តម លោក លោកស្រី** ជ្រាបថា កន្លងមកមានអង្គភាព និងមន្ទីរកសិកម្មមួយចំនួន បានលើកសំណើមកក្រសួង ដើម្បីសុំជម្រះចេញពីបញ្ជីសារពើភណ្ឌនូវទ្រព្យសម្បត្តិចាស់ ខូចទ្រុឌទ្រោមប្រើប្រាស់លែងកើត ក្នុងនោះក៏មានរថយន្ត និងម៉ូតូ ដែលមានស្លាកលេខជា **រាជការ ឬរដ្ឋ១៧** ដែលជាកម្មសិទ្ធិរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ក្រោយពីអនុវត្តនីតិវិធីហិរញ្ញវត្ថុរួចហើយ គណៈកម្មការអន្តរក្រសួង (ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសាលាខេត្តពាក់ព័ន្ធ) បានណែនាំឱ្យអង្គភាព ឬមន្ទីរកសិកម្មដែលជាអង្គភាពប្រើប្រាស់ទាំងនោះត្រូវដកហូតស្លាកលេខរថយន្ត និងម៉ូតូ ឱ្យរក្សាទុកនៅតាមអង្គភាព ឬមន្ទីរកសិកម្មរៀងខ្លួន។ ប៉ុន្តែ ជាការកត់សម្គាល់ រថយន្ត និងម៉ូតូដែលបានជម្រះចេញក្តី តែស្លាកលេខនៅមានការប្រើប្រាស់ដដែល ករណីខ្លះបានប្រើប្រាស់ក្នុងបទល្មើសផ្សេងៗថែមទៀតផង។ ដូច្នេះ ដើម្បីបញ្ចៀសបាននូវការប្រើប្រាស់ស្លាកលេខរថយន្ត និងម៉ូតូដែលបានជម្រះចេញពីបញ្ជីសារពើភណ្ឌរួចហើយទាំងនោះ ក្រសួងសូមស្នើដល់ **ឯកឧត្តម លោក លោកស្រី** ចាត់វិធានការបញ្ឈប់ការប្រើប្រាស់ដោយដកហូត និងរក្សាទុកឱ្យបានត្រឹមត្រូវ រួចរាយការណ៍ពីលទ្ធផល មកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (នាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ) យ៉ាងយូរត្រឹមថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៦ ជាកំហិត ដើម្បីក្រសួងមានវិធានការបន្ត។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម លោក លោកស្រី** ចាត់វិធានការអនុវត្តតាមខ្លឹមសារខាងលើដោយស្មារតីទទួលខុសត្រូវខ្ពស់ តាមការគួរ។

សូម **ឯកឧត្តម លោក លោកស្រី** ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ។ ២៩.៧.១៦

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**ចម្លងជូន :**

-អគ្គាធិការដ្ឋាន

"ដើម្បីជ្រាប"

-ឯកសារ កាលប្បវត្តិ

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨/ ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០

№ 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia. Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320